គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥

# សេចក្តីប្រកាសអត្ថបទស្តីពី

# ការពិចារណាលើការបង្កើនចំនួនអាសនៈរដ្ឋសភា

ការខ្វែងគំនិតគ្នារវាងគណបក្សជាប់ឆ្នោតទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិលើបញ្ហានៃការបង្កើនចំនួនអាសនៈរបស់រដ្ឋសភា ដែលស្នើដោយគណបក្សប្រឆាំងនៅតែបន្តភាពខ្វែងគំនិតគ្នា ដោយភាគីគណបក្សប្រជាជនកម្ពុជា មិនត្រឹមតែមិនយល់ព្រមបង្កើនចំនួនអាសនៈបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែបានស្នើឲ្យលុបចោលបញ្ញត្តិដែលពាក់ព័ន្ធនឹងរូបមន្តនៃការគណនាអាសនៈ ដែលមានចែងក្នុងមាត្រា៧ ៨ និងមាត្រា៩ ថែមទៀត ហើយចង់រក្សាចំនួនអាសនៈ១២៣នេះជារៀងរហូត ដោយគ្មានការកែប្រែឡើយ។ ទោះជាយ៉ាងណាក្តី គណបក្សសង្គ្រោះជាតិបានស្នើសុំឲ្យរក្សាទុកបញ្ញត្តិនេះដដែល និងស្នើឲ្យមានបង្កើនចំនួនអាសនៈយ៉ាងហោចណាស់៦អាសនៈបន្ថែមទៀត។ លោក ប៊ិន ឈិន ប្រធានក្រុមការងារកំណែទ្រង់ការបោះឆ្នោតខាងគណបក្សប្រជាជន កម្ពុជាបានបញ្ជាក់ថា « *គឺត្រូវរក្សាទុកចំនួន១២៣* អាសនៈ*នេះជារៀងរហូត*»។ ភាគីគណបក្សប្រជាជន បានបញ្ជាក់ជំហរ ថា ការផ្លាស់ប្តូរ គឺធ្វើឡើងសម្រាប់តែខេត្តដែលបង្កើតថ្មី គឺខេត្តត្បូងឃ្មុំដែលត្រូវកាត់យកអាសនៈចំនួន ៨អាសនៈចេញពីខេត្តកំពង់ចាមតែប៉ុណ្ណោះ។

នៅសម័យបោះឆ្នោតអាណត្តិទី១ ដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអ៊ុនតាក់ (UNTAC, the United Nations Transitional Authority for Cambodia) ចំនួនអាសនៈរបស់រដ្ឋសភាមានត្រឹមតែ១២០អាសនៈប៉ុណ្ណោះ ជាមួយនឹងប្រជាជនសរុប១០លាននាក់ និងអ្នកចុះឈ្មោះបោះឆ្នោតជិត៥លាននាក់។ នៅឆ្នាំ១៩៩៨ជាការបោះឆ្នោតជាតិសម្រាប់នីតិកាលទី២នៃរដ្ឋសភា ចំនួនអាសនៈ រដ្ឋសភាត្រូវបានបង្កើនមក១២២អាសនៈ គឺកើនបានចំនួនពីរអាសនៈបន្ថែម ដោយនៅឆ្នាំ១៩៩៨ ប្រជាជនកម្ពុជាបានកើនឡើងរហូតដល់ជាង១១លាននាក់ ហើយប្រជាជនដែលបានចុះឈ្មោះ បោះឆ្នោត មានរហូតដល់៥លាន និង៤សែននាក់។ បន្ទាប់មក នៅឆ្នាំ២០០៣ជាការបោះឆ្នោតជាតិ សម្រាប់នីតិកាលទី៣នៃរដ្ឋសភា ចំនួនអាសនៈ១២២ ត្រូវបានបង្កើនឡើងចំនួន១អាសនៈបន្ថែមទៀត ដូច្នេះអាសនៈសរុបរបស់រដ្ឋសភាសម្រាប់នីតិកាលទី៣ មានចំនួន១២៣អាសនៈ។ ប្រជាជនកម្ពុជាសរុប ក្នុងឆ្នាំ២០០៣ មានប្រហែល១៣លាននាក់ និងប្រជាជនមានក្នុងបញ្ជីឈ្មោះបោះឆ្នោតមានប្រមាណជាង ៦លាននាក់។

ដោយឡែកសម្រាប់ការបោះឆ្នោតជាតិសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ក្នុងឆ្នាំ២០០៨ និងសម្រាប់

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

នីតិកាលទី៥ ក្នុងឆ្នាំ២០១៣កន្លងទៅនេះ ចំនួនអាសនៈរដ្ឋសភាមិនត្រូវបានបង្កើន សូម្បី១អាសនៈ ហើយចំនួនប្រជាជនកម្ពុជាសរុប មានរហូតដល់ទៅប្រហែល១៥លាននាក់ទៅហើយ ជាមួយនឹងចំនួនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត រហូតដល់ជាង៩លាននាក់ (ក្បែរ១០លាននាក់)។

មានមូលហេតុសំខាន់ៗ ដែលភាគីធ្វើការងារពាក់ព័ន្ធនឹងការបោះឆ្នោត រួមមានគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងអ្នកជំនាញ (លើកលែងតែគណបក្សប្រជាជន) ក្នុងជំនួបនៃកិច្ចពិភាក្សាតុមូល ស្តីអំពី*សេចក្តីស្នើ/ស្នើច្បាប់វិសោធនកម្មលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ ប្រព័ន្ធបោះឆ្នោត និងរូបមន្តនៃការបែងចែកអាសនៈ* ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤ នៅសណ្ឋាគារ សាន់វេយ៍[1] យល់ឃើញថា ការបង្កើនចំនួនអាសនៈ និងការរៀបចំការបែងចែកអាសនៈរដ្ឋសភាតាមមណ្ឌលរាជធានី-ខេត្តមួយចំនួនសាឡើងវិញ។

## ក. និដ្ឋភាពផ្លូវច្បាប់ ដោយផ្អែកលើរូបមន្តនៃការគណនា

ផ្អែកលើបញ្ញត្តិនៃមាត្រា៧ និងមាត្រា៨នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានដាក់កាតព្វកិច្ចឲ្យគណៈកម្មការកែសម្រួលចំនួនអាសនៈរដ្ឋសភា ដែលត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ស្នើដោយទីស្តីការគណៈ រដ្ឋមន្ត្រី ក្រោមបញ្ញត្តិមាត្រា៧នៃច្បាប់ស្តីពី ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបង្កើតគណៈកម្មការមួយដើម្បីធ្វើការងារពាក់ព័ន្ធនឹងការកែប្រែចំនួនអាសនៈរបស់រដ្ឋសភា និងបែងចែកអាសនៈតាមខេត្តក្រុង។[2] ផ្អែកតាមបញ្ញត្តិនៃមាត្រានេះ គណៈកម្មការដែលបង្កើតឡើងដោយព្រះរាជក្រឹត្យនេះ ជារៀងរាល់ឆ្នាំទី៣ នៃនីតិកាលនីមួយៗរបស់រដ្ឋសភា ត្រូវធ្វើរបាយការណ៍ និងធ្វើសំណើអំពីការបន្ថែមអាសនៈ ឬរក្សាទុក ចំនួនអាសនៈដដែលជូនរាជរដ្ឋាភិបាល ដោយផ្អែកទៅលើស្ថានភាពប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច។ ដូច្នេះ គណៈកម្មការនេះមានកាតព្វកិច្ច ឬភារកិច្ចចំបងមួយ គឺត្រូវសិក្សាស៊ីជម្រៅ ទៅលើការងារកែប្រែចំនួនអាសនៈ និងបែងចែកអាសនៈតាមរាជធានី-ខេត្ត របស់រដ្ឋសភាសម្រាប់នីតិកាល បន្ទាប់ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃការវិវឌ្ឍន៍របស់ប្រទេស ដូចជាស្ថានភាពប្រជាសាស្ត្រ ភូមិសាស្ត្រនៃខេត្តនីមួយៗ ស្ថានភាពជាក់ស្តែងរបស់សង្គម និងការរីកធំធាត់វិស័យសេដ្ឋកិច្ចកម្ពុជា។ គណៈកម្មការនេះមានកាតព្វកិច្ចសំខាន់មួយទៀត គឺរៀបចំធ្វើសេចក្តីព្រាងច្បាប់ស្តីការកែប្រែចំនួនអាសនៈ និងការបែងចែកចំនួនអាសនៈដាក់ជូនរដ្ឋសភាដើម្បីអនុម័ត។

ខាងក្រោមនេះ ជាការគណនាសាកល្បងរកចំនួនអាសនៈថ្មីរបស់រដ្ឋសភា ដោយផ្អែកលើរូបមន្តក្នុង

---

[1] កិច្ចប្រជុំតុមូលដែលមានការចូលរួមដែលមានការចូលរួមពី សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ប្រធាន និងក្រុមការងារគណៈកម្មការកំណែទម្រង់បោះឆ្នោតមកពីគណៈសង្គ្រោះជាតិ គណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សសម្ព័ន្ធដើម្បីប្រជាធិតេយ្យ គណបក្សខ្មែរ ឈប់ក្រ និងគណបក្សសាធារណរដ្ឋខ្មែរ អ្នកចំនាញផ្នែកច្បាប់ សង្គម មេធាវី និងអ្នកវិភាគឯករាជ្យ និងអ្នកសារព័ត៌មានជាច្រើន។

[2] សូមអានមាត្រា៧ នៃច្បាប់ ស្តីពីច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

មាត្រា៩នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយមិនគិតចំនួនសល់ ដោយយកតួរលេខចំនួនប្រជាជនកម្ពុជាក្នុងឆ្នាំ២០១៣ និងចំនួនប្រជាជនកម្ពុជាប៉ាន់ប្រមាណសម្រាប់ឆ្នាំ២០១៧ (ប្រហែល១៦លាននាក់) ជាគោល។ ការគណនាខាងក្រោមនេះ គឺយកតួរលេខប្រជាជនកម្ពុជាឆ្នាំ២០១៣ ចំនួនប្រជាជនកម្ពុជា នៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមកនេះ (សម្រាប់នីតិកាលទី៥ ឆ្នាំ២០១៣) និងចំនួនប្រជាជនកម្ពុជាសរុបដែលអាចនឹងកើនឡើងប្រហែល១៦លាននាក់នៅឆ្នាំ២០១៧ខាងមុខ។

$$\frac{\text{ប}_{\text{ម}}}{\text{ច}_{\text{ម}}} = \text{ផ}$$

$\text{ប}_{\text{ម}}$ ជាចំនួនប្រជាពលរដ្ឋខ្មែរ នៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមកនេះ។

$\text{ច}_{\text{ម}}$ ជាចំនួនអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន។

$\text{ផ}$ ជាផលចែកប្រភាគដោយពុំគិតចំនួនសល់។

$$\frac{\text{ប}_{\text{ប}}}{\text{ផ}} = \text{ច}_{\text{ថ}}$$

$\text{ប}_{\text{ប}}$ ជាចំនួនចំនួនប្រជាជនខ្មែរបច្ចុប្បន្ន។

$\text{ច}_{\text{ថ}}$ ចំនួនអាសនៈថ្មីដោយពុំគិតចំនួនសល់។

ក្នុងការរកចំនួនតាមខេត្ត ក្រុង ត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

$$\frac{\text{ប}}{\text{ផ}} = \text{ច}$$

$\text{ប}$ ជាចំនួនប្រជាពលរដ្ឋខ្មែរក្នុងខេត្ត/រាជធានី

$\text{ផ}$ ជាផលចែកប្រភាគដែលបានមកពីការគណនាខាងលើ

$\text{ច}$ ជាចំនួនអាសនៈថ្មីក្នុងខេត្ត/រាជធានី។

ដោយប្រើរូបមន្តដែលមានចែងក្នុងមាត្រា៩ ដូចខាងលើ មកត្រឹមឆ្នាំ២០១៤ ចំនួនអាសនៈត្រូវបានគណនាដូចខាងក្រោម៖

$$\frac{\text{១៤,៧៣៥,៤៤៣ នាក់}^{3}}{\text{១២៣}} = \text{១១៩,៨០០ នាក់}$$

$$\frac{\text{១៦,000,000 នាក់}^{4}}{\text{១១៩,៨០០ នាក់}} = \text{១៣៣ អាសនៈ}$$

[3] តារាងស្ថិតិ ប្រជាពលរដ្ឋនិងចំនួនការិយាល័យបោះឆ្នោតប៉ាន់ស្មានសាម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៣, គជប, ១៣ កញ្ញាឆ្នាំ២០១៣។

[4] ជាចំនួនប្រជាជនប៉ាន់ប្រមាណទុកថា អាចនឹងមានកំណើនសម្រាប់ឆ្នាំ២០១៧ ឬ២០១៨។

បើទោះជាការគណនាខាងលើបានរកឃើញថា ចំនួនអាសនៈ រដ្ឋសភា ត្រូវកើនឡើងដល់ ១៣៣ អាសនៈក៏ពិតមែន ជម្រើសដ៏ល្អបំផុត ចំនួនអានៈ៤បន្ថែម គួរត្រូវបានបង្កើនលើចំនួនអាសនៈ១២៣ ដែលមានបច្ចុប្បន្ន នៅតាមមណ្ឌលនីមួយៗដូចខាងក្រោម ក្នុងន័យស្របតាម និងឲ្យមានសមាមាត្រនឹងកំណើន ចំនួនអ្នកមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងភាពសមហេតុផលនៃទំហំសកម្មភាពសង្គម និងសេដ្ឋកិច្ច និងស្ថានភាពជាក់ស្តែងពិតប្រាកដនៃខេត្តទាំងនោះ។ អាសនៈបន្ថែមថ្មីចំនួន៤អាសនៈ គួរទទួលបានទៅលើខេត្ត ព្រះសីហនុ ឧត្តរមានជ័យ ព្រះវិហារ និងខេត្តសៀមរាប។

| ល.រ | ឈ្មោះរាជធានី/ខេត្ត | ចំនួនប្រ.ជ.មានសិទ្ធិបោះឆ្នោតក្នុងបញ្ជី ឆ្នាំ២០១៤ | ចំនួនអាសនៈ អាណត្តិទី៥ | អនុសាសន៍ |
|---|---|---|---|---|
| ១ | ឧត្តរមានជ័យ | ១៣៨,៤៦៥ | ១ | ២ |
| ២ | ព្រះសីហនុ | ១២៦,២៤០ | ១ | ២ |
| ៣ | ព្រះវិហារ | ១២៦,៨៨១ | ១ | ២ |
| ៤ | ត្បូងឃ្មុំ | ៥៦១,២៩៤ | កាត់ពីខេត្តកំពង់ចាម ៧អាសនៈ | |
| ៥ | សៀមរាប | ៥៨២,៦៨០ | ៦ | ៧ |
| ៦ | កំពង់ចាម | ៧៣៨,២៩៥ | ១៨ | ១១ |

## ខ. *ស្ថានភាពប្រជាសាស្ត្រនៃប្រទេសកម្ពុជា*

ផ្អែកលើការប្រៀបធៀបគ្នា រវាងតួរលេខនៃចំនួនប្រជាជនកម្ពុជាទាំងបីប្រភេទនៃឆ្នាំ១៩៩៨ និងឆ្នាំ២០១៤ រួមមានៈ (១)*ចំនួនប្រជាជនសរុប (២)ចំនួនប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ និង (៣)ចំនួនប្រជាជនដែលបានចុះឈ្មោះបោះឆ្នោត* ក្នុងឆ្នាំទាំងពីរនេះ ចំនួនអាសនៈរដ្ឋសភាជាតិកម្ពុជានៅនីតិកាលខាងមុខ គួរតែត្រូវបង្កើនជាចាំបាច់។ ខាងក្រោមនេះ គឺជាការប្រៀបធៀបលើកត្តាប្រជាសាស្ត្រទាំងបីប្រភេទ រវាងស្ថិតិឆ្នាំ១៩៩៨ និងស្ថិតិឆ្នាំ២០១៤។

តាមស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន ចំនួនប្រជាពលរដ្ឋកម្ពុជាគ្រប់អាយុបោះឆ្នោត (ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ) និងប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោតរួចមកហើយ ចេញផ្សាយនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបង្ហាញថា *ទី១* ចំនួនប្រជាជនកម្ពុជាសរុបបានកើនឡើងដល់១៥លាននាក់ បើគិតមកត្រឹមឆ្នាំ២០១៤ (១៥,០១២,៩៥៩ នាក់)។[5] ចំនួនប្រជាជនកម្ពុជាសរុបបានកើនឡើងរហូតដល់ជាង៣លាន៥៧ម៉ឺននាក់ បើធៀបជាមួយចំនួនប្រជាជនកម្ពុជាសរុបក្នុងឆ្នាំ១៩៩៨ ដែលមានត្រឹមតែជាង១១លាននាក់ប៉ុណ្ណោះ។ *ទី២* ចំនួនប្រជាជនដែលគ្រប់អាយុបោះឆ្នោតសរុប (អាយុអាចទទួលបានសិទ្ធិបោះឆ្នោត) គឺមានការកើនឡើងខ្ពស់ រហូតដល់ជិត១០លាននាក់ (៩.៩៥១.៩១៥នាក់) នៅក្នុងឆ្នាំ២០១៤។ ចំនួននេះបានកើនឡើងរហូតដល់ជាង៤

[5] ស្ថិតិប៉ាន់ប្រមាណដោយ គជប ខែសីហា ឆ្នាំ២០១៤។

លាន៤៦ម៉ឺននាក់ បើធៀបនឹងចំនួនប្រជាជនកម្ពុជាដែលមានអាយុគ្រប់បោះឆ្នោតនៅឆ្នាំ១៩៩៨ ដែលមានត្រឹមតែ៥,៤៨៨,០២៩នាក់ប៉ុណ្ណោះ។[6] *ទី៣* ចំនួនប្រជាពលរដ្ឋកម្ពុជា ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតជាផ្លូវការបច្ចុប្បន្នមានរហូតដល់៩.៨០១.៥៣៥នាក់។[7] ចំនួនប្រជាពលរដ្ឋកម្ពុជាដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៥នៃរដ្ឋសភាឆ្នាំ២០១៣កន្លងទៅនេះ មានរហូតដល់៩,៦៧៥,៤៥៣នាក់។[8] ចំនួនដែលមានក្នុងបញ្ជីឈ្មោះបោះឆ្នោតនេះបានកើនឡើងចំនួន៤លាន២៧ម៉ឺននាក់ បើធៀបនឹងចំនួនប្រជាជនកម្ពុជា ដែលឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការនៃឆ្នាំ១៩៩៨ ដែលមានត្រឹមតែ៥.៣៩៥.៥៩៥នាក់។ កំណើនចំនួនប្រជាពលរដ្ឋខ្មែររាប់លាននាក់ ពោលគឺកើនពីជាង១១លាននាក់ រហូតដល់លើសពី១៥លាននាក់សម្រាប់ឆ្នាំ២០១៤ និងអាចលើសពី១៦លាននាក់ នៅការបោះឆ្នោតសម្រាប់នីតិកាលទី៦ក្នុងឆ្នាំ២០១៨ខាងមុខ ចាំបាច់ត្រូវមានការកែប្រែចំនួនអាសនៈឲ្យសមាមាត្រជាមួយកំណើនប្រជាជន។

### ***គ. ស្ថានភាពសេដ្ឋកិច្ច***

នៅឆ្នាំ២០១៤នេះ កម្ពុជាបានរក្សាកំណើនសេដ្ឋកិច្ចរបស់ខ្លួនបានលើសពី៧ភាគរយ។ ផ្អែកតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាសន្យាថា ប្តេជ្ញារក្សាកំណើនសេដ្ឋកិច្ច ក្នុងរវាង៧ភាគរយក្នុងមួយឆ្នាំ។ ផ្អែកលើក្រសួងហិរញ្ញវត្ថុ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស,GDP) របស់កម្ពុជាឆ្នាំ២០១៤ អាចកើនឡើងរហូតដល់ជាង១៦ពាន់លានដុល្លារ ឬហូតដល់ ១៦.៥៤ពាន់លានដុល្លារអាមេរិក។ ក្រសួងបានព្យាករថា នៅឆ្នាំ២០១៥នេះ កម្ពុជានឹងអាចមានកំណើន ផ.ស.ស រហូតដល់ (៧,៤៤៤ពាន់លានរៀល) ស្មើនឹង១៨.២០ពាន់លានដុល្លារអាមេរិក ដោយផ្អែកលើកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់៧ភាគរយ។ យោងតាមច្បាប់ ស្តីពីការគ្រប់គ្រងថវិកាជាតិឆ្នាំ២០១៥ ចំណូលសរុបរបស់កម្ពុជាដែលគ្រោងនឹងប្រមូលបាន ក្នុងនោះរួមមានចំណូលចរន្ត និងចំណូលមូលធន (ចំណូលមូលធនក្នុងប្រទេស ក្រៅប្រទេស (មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស)) គឺមានរហូតដល់ទៅ២៣,២៤២,៨១៦លានរៀល ស្មើនឹង៥៦៨៣.៥៧ពាន់លានដុល្លារអាមេរិក (ប្រហែលប្រាំពាន់ប្រាំមួយរយប៉ែតសិបបីពាន់លានដុល្លារអាមេរិក)។

### ***ឃ. ស្ថានភាពភូមិសាស្ត្រនៃខេត្តនីមួយៗ ដែលគួរតែត្រូវបង្កើនចំនួនអាសនៈ***

១. **ខេត្តឧត្តរមានជ័យ:** ខេត្តនេះ អតីតជាខេត្តសមរភូមិសង្គ្រាម ប៉ុន្តែនៅក្នុងរយៈពេលជាងមួយទសវត្សកន្លងមកនេះ ខេត្តមួយនេះបានក្លាយជាខេត្តដ៏គួរឲ្យចាប់អារម្មណ៍មួយរបស់អ្នកវិនិយោគ លើដំណាំកសិកម្ម កសិឧស្សាហកម្ម និងប្រជាជនចំណាកស្រុកពីខេត្តផ្សេងៗ។ ចាប់តាំងពីសង្គ្រាមស៊ីវិលបានបញ្ចប់ទៅ ខេត្តនេះបានប្តូរមុខមាត់យ៉ាងច្រើន ហើយអ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងគេនោះ គឺតំលៃដីធ្លី និង

---

[6] ទូរលេខគឺធ្វើការប្រៀបធៀបរវាងចំនួនប្រជាជនសរុបឆ្នាំ២០១៤ និងចំនួនប្រជាជនសរុបឆ្នាំ១៩៩៨ (ជំរឿនទូទៅឆ្នាំ១៩៩៨ បោះពុម្ពលើកទី២ ខែកក្កដា ឆ្នាំ១៩៩៩ របស់ក្រសួងផែនការ)។

[7] ស្ថិតិប៉ាន់ប្រមាណដោយ គជប ខែសីហា ឆ្នាំ២០១៤។

[8] បញ្ជីបោះឆ្នោតផ្លូវការដែលត្រូវបានផ្តល់សុពលភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រកាសចុះថ្ងៃទី៣១ ធ្នូ ឆ្នាំ២០១៤។

កំណើនប្រជាជន បានហក់ឡើងយ៉ាងគំហុកនៅខេត្តមួយនេះ។ មានប្រជាជនប្រហែលជាង២២ម៉ឺននាក់កំពុងរស់នៅក្នុងខេត្ត គឺជាចំនួនប្រជាជនដ៏ច្រើន និងចរន្តនៃការរីកចំរើនសេដ្ឋកិច្ច ជាពិសេសនៅតាមបណ្តោយបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដែលជាហេតុផលសមរម្យមួយ គួរពិចារណាលើការបង្កើនអាសនៈនៅក្នុងខេត្តមួយនេះឲ្យបានចំនួនមួយអាសនៈបន្ថែមទៀត។ ខេត្តឧត្តរមានជ័យ បច្ចុប្បន្នមានអាសនៈរដ្ឋសភាតែមួយអាសនៈគត់ តំណាងឲ្យប្រជាជនជាង២២ម៉ឺននាក់។ បើធៀបជាមួយខេត្តមួយចំនួនដែលមានអាសនៈចំនួនតែមួយអាសនៈដែរ ដូចជាខេត្តកែប (មានប្រជាជនត្រឹមតែជិត៤ម៉ឺននាក់) ខេត្តប៉ៃលិន (មានប្រជាជនប្រមាណជាង៦ម៉ឺននាក់) ខេត្តឧត្តរមានជ័យ ត្រូវការបង្កើនអាសនៈបន្ថែមយ៉ាងហោចណាស់ឲ្យបាន១អាសនៈបន្ថែមទៀត ដើម្បីឲ្យសមស្របនឹងចំនួនប្រជាជនដ៏ច្រើនលើសលប់ ប៉ុន្តែចំនួនអាសនៈតិចទៅវិញ។

២. **ខេត្តព្រះសីហនុៈ** ជាខេត្តដែលមានសក្តានុពលលើវិស័យទេសចរណ៍លំដាប់ទី២នៅកម្ពុជា បន្ទាប់ខេត្តសៀមរាប។ ខេត្តនេះមានប្រជាជនរស់នៅជាង២០ម៉ឺននាក់។ សក្តានុពលវិស័យទេសចរណ៍ ធ្វើឲ្យខេត្តមួយនេះបានទាក់ទាញទាំងចំនួនប្រជាជនឲ្យមករស់នៅក្នុងខេត្តនេះ និងទាំងចំនួនភ្ញៀវទេសចរយ៉ាងច្រើនកុះករ។ ដោយសារសក្តានុពលផ្នែកសេដ្ឋកិច្ច គឺវិស័យទេសចរណ៍ ជាពិសេស ពីមួយឆ្នាំទៅមួយឆ្នាំបានធ្វើឲ្យខេត្តមួយនេះមានប្រជាជនមករស់នៅកាន់តែច្រើនឡើងៗ។ យោងទៅលើសក្តានុពល និងកំណើនប្រជាជនរបស់ខេត្ត ជាការសាកសមបំផុតដែលខេត្តមួយនេះ គួរបង្កើនអាសនៈឲ្យបានយ៉ាងតិចចំនួន១អាសនៈបន្ថែមទៀត។ ខេត្តព្រះសីហនុ បច្ចុប្បន្នមានអាសនៈរដ្ឋសភាតែមួយអាសនៈគត់ តំណាងឲ្យប្រជាជនជាង២០ម៉ឺននាក់ និងសក្តានុពលសេដ្ឋកិច្ចដ៏ធំរបស់វា។ បើធៀបជាមួយខេត្តមួយចំនួនដែលមានអាសនៈចំនួនមួយដែរ ដូចជាខេត្តកែប (មានប្រជាជនតែជិត៤ម៉ឺននាក់) ខេត្តប៉ៃលិន (មានប្រជាជនប្រមាណជាង៦ម៉ឺននាក់) ខេត្តព្រះសីហនុត្រូវការបង្កើនអាសនៈបន្ថែមយ៉ាងហោចណាស់ឲ្យបាន១អាសនៈបន្ថែមទៀត។

៣. **ខេត្តព្រះវិហារៈ** ព្រះវិហារជាខេត្តមួយដ៏ធំ តែមានប្រជាជនរស់នៅតិចជាងគេ បើធៀបជាមួយខេត្តមួយធំៗចំនួនទៀត។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ សន្ទុះនៃកំណើនប្រជាជន និងសដ្ឋកិច្ច ដូចជាវិស័យដីធ្លី ទេសចរណ៍ ព្រៃឈើ បានធ្វើឲ្យខេត្តមួយនេះជាទីចាប់អារម្មណ៍របស់ប្រជាជនខេត្តផ្សេងៗមកតាំងទីលំនៅក្នុងខេត្តនេះកាន់តែច្រើនឡើងគួរឲ្យកត់សំគាល់។ រហូតមកដល់ឆ្នាំ២០១៤នេះ ខេត្តព្រះវិហារមានប្រជាជនរស់នៅរហូតដល់ទៅជាង២២ម៉ឺននាក់។ ផ្អែកលើសក្តានុពលសេដ្ឋកិច្ច ចំនួនប្រជាជនច្រើន និងអំណោយផលលើវិស័យមួយចំនួនទៀត ខេត្តមួយនេះត្រូវការការកែសម្រួលចំនួនអាសនៈរដ្ឋសភាជាចាំបាច់។ ខេត្តព្រះវិហារ បច្ចុប្បន្នមានអាសនៈរដ្ឋសភាតែមួយអាសនៈគត់ប៉ុណ្ណោះ តំណាងឲ្យប្រជាជនជាង២២ម៉ឺននាក់។ បើធៀបជាមួយខេត្តមួយចំនួនដែលមានអាសនៈចំនួនមួយដែរ ដូចជាខេត្តកែប (មានប្រជាជនតែជិត៤ម៉ឺននាក់) ខេត្តប៉ៃលិន (មានប្រជាជនប្រមាណជាង៦ម៉ឺននាក់) ខេត្តព្រះវិហារត្រូវការបង្កើនអាសនៈបន្ថែមយ៉ាងហោចណាស់ឲ្យបាន១អាសនៈបន្ថែមទៀត។

៤. **ខេត្តសៀមរាបៈ** សៀមរាបជាខេត្តធំមួយ ក្នុងចំណោមខេត្តធំៗដទៃទៀត។ ខេត្តមួយនេះបានប្តូរមុខមាត់យ៉ាងខ្លាំងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោមនេះ។ វិស័យទេសចរណ៍ គឺជាវិស័យសំខាន់ដ៏សំខាន់បំផុតដែលធ្វើឲ្យខេត្តមួយនេះមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័យបែបនេះ។ វាជាខេត្ត ដែលអាចទាក់ទាញភ្ញៀវ

ទេសចរណ៍ជាតិ និងអន្តរជាតិបានច្រើនជាងគេបំផុត និងបានបង្កើតការងារដល់ប្រជាជនកម្ពុជាយ៉ាងច្រើន។ បច្ចុប្បន្ន ខេត្តនេះមានតែ៦អាសនៈនៃរដ្ឋសភាប៉ុណ្ណោះ ដែលចំនួននេះ គឺមិនសាកសមនឹងចំនួនប្រជាជន ដែលកំពុងតែកើនឡើងឥតឈប់ឈរនោះឡើយ។ រហូតមកដល់ពេលនេះ ខេត្តសៀមរាបមានប្រជពលរដ្ឋខ្មែរប្រហែល១លាននាក់កំពុងរស់នៅ ដែលស្មើរពាក់កណ្តាលនៃប្រជាជនសរុប គឺជាប្រជាជនចំណូលពីខេត្តផ្សេងៗនៃប្រទេសកម្ពុជា។ ការកើនឡើងយ៉ាងគំហុកលើការវិនិយោគលើវិស័យទេសចរណ៍ គឺជាកត្តាដែលជម្រុញឲ្យខេត្តមួយនេះ មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សបែបបនេះ។ ដូច្នេះផ្អែកលើសក្តានុពលរបស់ខេត្ត ចំនួនអាសនៈរដ្ឋសភាបច្ចុប្បន្ននៃខេត្តនេះ គួរពិចារណាបន្ថែមយ៉ាងហោចណាស់ចំនួន១ អាសនៈបន្ថែមលើចំនួនបច្ចុប្បន្ន។

៥. **ខេត្តត្បូងឃ្មុំ:** ជាខេត្តដែលទើបតែបង្កើតថ្មី ដោយបំបែកចញពីទឹកដីខេត្តកំពង់ចាម។ តាមតួរលេខចំនួនប្រជាជនដែលប៉ាន់ស្មានដោយ គ.ជ.ប ខេត្តត្បូងឃ្មុំ មានចំនួនប្រជាជនរស់នៅប្រមាណជាង៨សែននាក់ និងមានប្រជាជនដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតជិត៦០ម៉ឺននាក់ ដូចគ្នានឹងខេត្តសៀមរាបដែរ។ ដូច្នេះ អាសនៈរដ្ឋសភាចំនួន៧អាសនៈ គួរត្រូវកាត់ចេញពីខេត្តកំពង់ចាម ហើយដាក់បញ្ចូលឲ្យខេត្តត្បូងឃ្មុំ។ ខេត្តនេះ មានសក្តានុពលខាងផ្នែកសេដ្ឋកិច្ចគួរសម ប៉ុន្តែតិចតួចជាងសក្តានុពលនៃខេត្តសៀមរាប។

៦. **ខេត្តកំពង់ចាម:** កំពង់ចាម អាចចាត់ទុកថា ជាខេត្តដែលមានចំណាត់ថ្នាក់ល្អលំដាប់លេខ៣ លើសក្តានុពលផ្នែកសេដ្ឋកិច្ច ឬអាចថា ប្រហាក់ប្រហែលគ្នាជាមួយនឹងខេត្តបាត់ដំបង។ ខេត្តមួយនេះ មានសក្តានុពលទាំងកសិកម្ម កសិឧស្សាកម្ម និងឧស្សាហកម្ម។ ក្រោយពីផ្ទៃដីមួយផ្នែកធំត្រូវបានកាត់ចេញ និងបង្កើតជាខេត្តថ្មី គឺខេត្តត្បូងឃ្មុំ បច្ចុប្បន្នខេត្តកំពង់ចាមនៅមានប្រជាជនរស់នៅលើសពី១លាននាក់។ ខេត្តកំពង់ចាម គួររក្សាអាសនៈរដ្ឋសភានៅត្រឹមចំនួន១១អាសនៈយ៉ាងតិច។

### ខ. ***ការបង្កើនអាសនៈរដ្ឋសភា មិនប៉ះពាល់ដល់ទំហំកញ្ចប់ថវិកាជាតិ***

ទំហំថវិកាជាតិសរុបដែលរដ្ឋសភាទើបតែអនុម័ត សម្រាប់ឆ្នាំ២០១៥ គឺ៣.៨ពាន់លានដុល្លារអាមេរិក ហើយកញ្ចប់ថវិកាជាតិ ដែលរដ្ឋសភាទទួលបានយកទៅប្រើប្រាស់ គឺមានចំនួនត្រឹមតែ៣២លានដុល្លារអាមេរិក ឬស្មើនឹង០,៨ភាគរយនៃថវិកាជាតិសរុបប៉ុណ្ណោះ។ ក្នុងករណីអាសនៈរដ្ឋសភាចំនួន៤ នឹងត្រូវបានបង្កើននោះ កញ្ចប់ថវិកាជាតិប្រហែល១លានដុល្លារនឹងត្រូវបានបញ្ចូលបន្ថែម។ កញ្ចប់ថវិកាជាតិដែលរដ្ឋសភាទទួលបានទំហំ រវាង៣៣ ឬ៣៤លានដុល្លារអាមេរិក គឺជាចំនួនដែលវាតិចជាងកញ្ចប់ថវិកាជាតិដែលត្រូវបានអនុម័តឲ្យដល់ស្ថាប័នមួយនៃស្ថាប័ននីតិប្រតិបត្តិមួយគត់ គឺទីស្តីការគណៈរដ្ឋមន្ត្រីដែលទទួលបានរហូតដល់ទៅ១១០លានដុល្លារអាមេរិកសម្រាប់ឆ្នាំ២០១៥នេះ។ ដូច្នេះ ខ្ទង់ចំណាយស្ថាប័នរដ្ឋសភាគួរត្រូវបន្ថែម១លានដុល្លារ និងកាត់បន្ថយការចំណាយដ៏សន្ធឹកសន្ធាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រីជំនួសវិញ។

ការបង្កើនសមត្ថភាព លទ្ធភាព និងថវិកាដល់រដ្ឋសភា និងអ្នកតំណាងរាស្ត្រ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីបង្កើនសកម្មភាពត្រួតពិនិត្យការអនុវត្តន៍ច្បាប់របស់រដ្ឋាភិបាល និងបង្កើតសកម្មភាពចុះជួយម្ចាស់ឆ្នោតតាមមណ្ឌលនីមួយៗ។ ចំនួនសមាជិករាជរដ្ឋាភិបាលបច្ចុប្បន្នដែលរួមមាន ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការដែលសរុបប្រមាណ២៤៥នាក់ គឺជាចំនួនដ៏ច្រើន។ នេះមិនទាន់រាប់បញ្ចូលចំនួនអនុរដ្ឋលេខាធិការ និងទីប្រឹក្សាដែលតែងតាំងបន្ថែមលើមុខងារ រាជរដ្ឋាភិបាលដែលមានចំនួនយ៉ាងច្រើននៅតាមក្រសួង ឬស្ថាប័នជាតិនីមួយៗផង។

រូបមន្តនៃការគណនាបង្កើនចំនួនអាសនៈរដ្ឋសភា មិនគួរត្រូវបានលប់ចេញពីច្បាប់ក្នុងពេលនេះឡើយ។ រូបមន្តគណនាបង្កើនអាសនៈរដ្ឋសភា គួរត្រូវបានប្រើប្រាស់ច្រើនអាណត្តិបន្តទៀត រហូតដល់អាសនៈរដ្ឋសភាមានតុល្យភាពជាមួយចំនួនសមាជិករដ្ឋាភិបាល។ ចំនួនអាសនៈរដ្ឋសភា គួរត្រូវបានបន្តបង្កើនរហូតដល់២០០អាសនៈរដ្ឋសភា។ នៅពេលនោះ ការពិភាក្សាលុបរូបមន្តនេះ គួរត្រូវដល់ពេលពិចារណា។

ជារួម ពិភាក្សាលើបញ្ញត្តិ ស្ដីពីការបង្កើនចំនួនអាសនៈរដ្ឋសភា ឬការប៉ុនប៉ងលុបចោលរូបមន្តនៃការគណនាបង្កើនចំនួនអាសនៈរដ្ឋសភា គឺមិនមែនធ្វើឡើងដោយគ្រាន់តែ មានការចូលរួមតែគណបក្សជាប់ឆ្នោតតែពីរប៉ុណ្ណោះទេ គឺវាត្រូវការការចូលរួមពិភាក្សាពីភាគីដែលពាក់ព័ន្ធនឹងការងារបោះឆ្នោត និងអ្នកជំនាញទាំងអស់ក្នុងការពិភាក្សាលើបញ្ហានេះ។ ដោយឡែក យើងចង់ឲ្យមានការបកស្រាយពន្យល់ពីគណបក្សប្រជាជនកម្ពុជាថាតើ គាត់ប្រើរូបមន្តអ្វី ឬឈរលើមូលដ្ឋានអ្វីដើម្បីគណនាអាសនៈសម្រាប់ការគណនាអាសនៈខេត្តត្បូងឃ្មុំ ដើម្បីឲ្យទទួលបានចំនួន៨អាសនៈរដ្ឋសភាសម្រាប់ខេត្តថ្មីមួយនេះ? គ្មានមូលហេតុណា តម្រូវឲ្យលុបរូបមន្តគណនាបង្កើនចំនួនអាសនៈ ហើយកំណត់ឲ្យរក្សាទុកត្រឹមតែ១២៣អាសនៈតំណាងរាស្ត្រជារៀងរហូតនោះទេ។ រូបមន្តនេះគួរត្រូវបានប្រើច្រើនអាណត្តិបន្តទៅទៀត រហូតដល់ចំនួនអាសនៈរដ្ឋសភា អាចកើនឡើងដល់២០០អាសនៈសិន។ ការបង្កើនចំនួនអាសនៈរដ្ឋសភា គឺដើម្បីធានានូវតុល្យភាព រវាងចំនួនសមាជិករដ្ឋសភា និងចំនួនសមាជិករាជរដ្ឋាភិបាល។ ការបង្កើនចំនួនអាសនៈរដ្ឋសភាពជាតិពី១២៣នាក់ ដែលមានតាំងពីឆ្នាំ២០០៣ មកត្រឹម១២៧អាសនៈ (៤អាសនៈបន្ថែម) សំរាប់នីតិកាលខាងមុខ គឺពិតជាសមរម្យ។

ការបង្កើនចំនួនអាសនៈ គឺពិតជាសមហេតុផលបំផុត ទាំងហេតុផលស្របតាមបញ្ញត្តិច្បាប់ជាធរមាន ស្ថានភាពប្រជាសាស្ត្រ សេដ្ឋកិច្ច និងដើម្បីពង្រឹងនូវតួនាទី និងសកម្មភាពរបស់រដ្ឋសភា។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

| | | |
|---|---|---|
| ១ .លោក គល់ បញ្ញា | នាយកប្រតិបត្តិ នៃអង្គការខុមហ្រ្វែល | ០១២ ៩៤ ២០ ១៧ |
| ២.លោក យឿង សុធារ៉ា | មន្ត្រីផ្នែកច្បាប់ និងអង្កេតខុមហ្វ្រែល | ០១២ ៣៨០ ០៨៥ |
| ៣. លោក ស៊ិន ទិត្យសីហា | មន្ត្រីផ្នែកអង្កេតខុមហ្វ្រែល | ០១២ ២៥២ ៦៦១ |
| ៤. លោក សួន យុធ្យា | មន្ត្រីផ្នែកតស៊ូមតិខុមហ្វ្រែល | ០៨៨ ៨ ១៤២ ៧៨៣ |

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។